**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខៈ ១៧ អយក.គល.ទន

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការផ្គត់ផ្គង់សម្ភារការិយាល័យ ថវិកាកម្មវិធីឆ្នាំ២០១៨ ផ្នែកអប់រំ និងយុវជន និងកីឡា ជំពូក៦០ គណនី៦០០២ អនុគណនី៦០០២១ របស់អង្គភាពថវិកានាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ នាយកដ្ឋានបុគ្គលិក និងអគ្គនាយដ្ឋានកីឡា

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សម្ភារការិយាល័យ ថវិកាកម្មវិធីឆ្នាំ២០១៨ ផ្នែកអប់រំ និងយុវជន និងកីឡា ជំពូក៦០ គណនី៦០០២ អនុគណនី៦០០២១ របស់អង្គភាពថវិកានាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ កម្មវិធីទី៥ អនុកម្មវិធីទី១២ ចង្កោមសកម្មភាពទី២ នាយកដ្ឋានបុគ្គលិក កម្មវិធីទី៥ អនុកម្មវិធីទី២ ចង្កោមសកម្មភាពទី១ និងអគ្គនាយដ្ឋានកីឡា កម្មវិធីទី៣ អនុកម្មវិធីទី១ ចង្កោមសកម្មភាពទី១។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្របតាមបទបញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានអគាររដ្ឋបាលថ្មី(សាលាបឋមសិក្សាចៅពញាហុក)ជាន់ទីពីរ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ២១០ ៤៦៤ / ០២៣ ២២០ ៩២៧ ទូរស័ព្ទ/ទូរសារលេខ៖០២៣ ២១៥ ២០២ អ៊ីមែល: procurement@moeys.gov.kh គេហទំព័រ www.moeys.gov. kh/procurement ចាប់ពីថ្ងៃ ០៥ ខែ មិថុនា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយឯកសារដេញថ្លៃនូវ **លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ** ដែលមានទឹកប្រាក់ចំនួន **៦ ៦០៨ ៩៤០រៀល (ប្រាំមួយលាន ប្រាំមួយរយប្រាំបីពាន់ ប្រាំបួនរយសែសិបរៀលគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង ៤:០០ រសៀល ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើនៅវេលាម៉ោង
ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម តាមរយៈអាសយដ្ឋានខាងលើ ដើម្បីទិញឯកសារ ដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៨
ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
រដ្ឋលេខាធិការ

**ពិត_ចំណាន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ